Khmer Story Lovers

# បក្សាមរណៈ

ប្រលោមលោកប្រឌិតតាមសម័យបុរាណ ចិន

ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ ច័ន្ទ ពុធ សៅរ៍



អ្នកប្រែសម្រួល: អ.គឹមសាន

តម្លៃ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
«មាតុភូមិ»
ភ្នំពេញ

លេខ ៣

ផងនេះ ឈ្មោះវុនកាំង់យីមានចិត្តឈឺចាប់ ហើយភ័យស្រណោះណាស់ ព្រោះជីវិតជាកំលោះមិនល្អទេ ក៏គាយមិនព្រមឲ្យអ្នកក្រៅនិយាយឲ្យគេឲ្យយកក្រុមគ្រួសាររបស់ខ្លួនដែរ ។ ខណៈនោះ សៃម៉ោនទឹកក្បាលគេថា

– ល្អណាស់ ! ។ !

ហើយគាត់ផឹកជាវុនកាំង់យីចាក់ចេញ ! វុនកាំង់យីប្រញាប់ណាស់ថយក្រោយគេចផុតថ្ងៃជាប់ តែឥឡូវដាវរបស់សៃម៉ោនទឹកម៉ែសណាស់ ករកាយមាណកមិនទាន់ធ្លាក់ដល់ជីវិត, ខ្លួនជាប់បាក់ត្រូវជើងខ្លួនគាយស្រេច ។ សៃម៉ោនទឹកលោតជាប់មួយគ្នា ក៏ផែកថយក្រោយវិញភ្លាម ។ លុះវុនកាំង់យីធ្លាក់ដល់ដី គាត់ចុះចូលតាមឈ្មោះដូចមានខ្យល់បក់មកពីខ្លួនក្រឡាក់ស្រែក ។ គាយចុះមើលស្រាប់តែឈាមរបស់ស្រែកកួយ ។ ព្រោះនៅត្រង់ជើងខ្លួន មានប៉ែនមូលមួយប៉ុនមាត់ថែវ គឺសៃម៉ោនទឹកបាញ់ជាប់ចំពោះរបស់គាយជាផ្ទើនមួយគ្រាន់សាច់ តែពុំបានចាណ្ដាលឈូសក្បៀរ ។ ប្រសិនបើសៃម៉ោនទឹកគ្រវ៉ាត់ឲ្យខ្លាំងបន្តិច ខ្លួនគាយច្បាស់ជាត្រូវធ្លាយពេញពោះស្លាប់មិនខាន ។ វុនកាំង់យីមានទឹកមុខស្លេកស្លាំង ភ័យមាត់និយាយលែងរួច ។ គាត់ហ្សីនយើងគិតសើចសព្វសើរ សៃម៉ោនទឹកក្រោលនិ, អង្គុយត្រាំ [illegible]

- អស្ចារ្យមែន !

សន្ទុះដាវរបស់ជនត្រកូលសេរីហ័សណាស់ ទោះជឹងថាចាក់តម្រង់កន្លែងណា ក៏នៅតែពុំអាចរ
ពាន់វៃ។ ។ ស៊ីឈឹងនិងវុនយូវៀជាក់ថា ខ្លួនគ្មានសមត្ថភាពអាចធ្វើដូច្នេះបានទេ ។ ប៉ុន្ត
មើលមុខគ្នាដោយក្តីបារម្ភនិងសោកស្តាយ ។ គេនឹកក្នុងចិត្តថាជននេះមានវិជ្ជាខ្ពង់ខ្ពស់ចម្លែកណា
រកអ្វីប្រៀបផ្ទឹមពុំបានឡើយ, ពួកយើងថ្ងៃនេះសិយមែន ប្រសិនបើយកបានបញ្ហាដែកសិរីទិព្វមុននេះប
ប្រហែលកាចសង់សឹកបានពុំខាន ។

ពេលនេះសៃយានទីគ្រហឹមហ៊ឹះបោះជំហានប្រុងចេញដំណើរ ។ នារីម្នាក់នៅក្នុងក្រុ
ទឹកកកស្រែកថា :

-លោកសៃ ! ឈប់សិន !

សៃយានទីបែរមកសួរ :

មានការអ្វីទៀតឬ ?

នារីនេះឈ្មោះហ្វាក់នជី ។ នាងលំអោនកាយតប :

-អម្បាញ់មិញ ដោយសារលោកអត់អធ្យាស្រ័យ ទើបបងរួមគ្រូនាងខ្ញុំគ្មានរបួស ។ ចំពោ
អំពើនេះ, ក្រុមក្នុងទឹកកកនាងខ្ញុំត្រេកអរណាស់ តែនៅសៀងឆ្ងល់រឿងមួយ គឺថាបន្ទះដែកដែ
លោកយកនោះ ពិតជាបញ្ហាដែកសិរីទិព្វមែនឬ ?

សៃយានទី បញ្ចេញទឹកមុខស្រស់ញញឹម ហើយពើនក្រូងយ៉ាងក្រអឺតថា :

- បើមែនយ៉ាងម៉េច បើមិនមែនយ៉ាងម៉េច ?

ហ្វាក់នជីតប :

-បើមិនមែនជាបញ្ហាដែកសិរីទិព្វទេ យើងខ្ញុំនឹងទំកាមរកទៀត តែបើផ្ទុយទៅវិញ លោក
ដូច្នេះហាក់ពុំសមរម្យសោះ ។

ទិនក់នជុនប្រញាប់ស្រែកគំហកថា :

-អូនហ្វូ សូមកុំមាត់ច្រើនពេក !

ដំបូងសៃយានទីហាក់ទឹងសម្បារតែបន្ទាប់មកក៏ទោរទន់ចិត្តវិញភ្លាម គេធ្លាប់ដឹងថា គា
កាន់ចិត្តកាចសាហាវយង់ឃ្នងណាស់ តែងប្រព្រឹត្តអំពើអ្វីតាមតែនឹកឃើញគ្មានគោរពច្បាប់ពិភ

គុនឡើយ ។

អ្នកក្លាហានដែលគាត់បានកាប់សម្លាប់រាប់មិនអស់ទេ ប៉ុន្តែដោយសារមានកម្រិតយុទ្ធសិល្បៈខ្ពស់ និងមានដំណើរមិនទៀងទាត់ ទើបសត្រូវទាំងឡាយពុំអាចតាមរំខានគាត់បាន ។ រហូតប៉ុន្មានឆ្នាំនេះគាត់សម្លាប់សត្រូវជិតអស់ហើយ អ្នកដែលនៅសល់សុទ្ធសឹងវង្វេងខ្សោយ ម្ល៉ោះហើយគ្មាននរណាហ៊ានមានគំនិតបង្ករសង្គ្រាមសឹកទៀតឡើយ ។ តែចំឡែកអ្វីថ្ងៃនេះសត្រូវពុំដឹងមកពីណា នាំគ្នាវាយលុកគាត់ប៉ុន្តែគាត់ពុំបានបណ្ដាលរបួសឲ្យនរណាទេ ។ នេះជាអំពើល្អមួយក្នុងភាគជីវិតរបស់គាត់ !

គេមិនស្គាល់ថានាងក្រកូលហ្វូ ហ៊ានពោលពាក្យប្រទេចគេះបោះបោកឲ្យគាត់យ៉ាងនេះសោះ ។ មិនត្រឹមតែពួកសិស្សក្តីទឹកកកប៉ុណ្ណោះទេ សូម្បីប្ដីប្រពន្ធស៊ីឈីន ក៏ភ័យព្រួយជំនួសនាងក្រមុំដែរ ។

ខណៈនោះស៊ែយានទីលើកបន្ទះដែកផុតក្បាល ស្រែកខ្លាំង ១ ថា:

-បញ្ហាដែកសំរិទ្ធនឹងប្រព្រឹត្តតាមសំណូមពរ !

គាត់ប្រែបន្ទះដែកម្ដងទៀត ស្រែកបន្ត:

- ស៊ែយានទីនៅភ្នំម៉ាង !

ស្រែកចប់គាត់ទម្លាក់ដៃចុះក្រោមវិញ ហើយពោល:

- ដែកសំរិទ្ធនេះកម្រមានណាស់ ទោះកាំបិតឬដាវ ក៏មិនអាចកាត់ដាច់ដែរ ។

និយាយបណ្ដើរ ដកដាវកាប់បន្ទះដែកបណ្ដើរ ឮសូរគឹង !

ផ្លែដាវធ្លាក់ជាពីរ តែបន្ទះសំរិទ្ធ នៅរលោងស្រិលគ្មានដែលបន្តិចសោះ ។

គាត់ធ្វើមុខម៉ាំ ចំហកខ្លាំង ១ ថា :

- ហេតុអ្វីនាងឯងថាយើងប្រព្រឹត្តអំពើមិនសមរម្យ ?

ហ្វួងជាឆ្លើយតបសម្រួលៈ

- នាងខ្ញុំធ្លាប់ ឮអ្នកគុននិយមដំណាលថា បញ្ហាដែកសំរិទ្ធរបស់លោកមានបីបន្ទះ ហើយបានចែកជូនមិត្តភក្តិបីនាក់ដែលមានឧបការគុណលើរូបលោក ។ លោកបានបញ្ជាក់ថាឲ្យតែអ្នកណាកាន់ផ្លាកបញ្ហានេះមកប្រគល់ដល់ផ្ទាល់ដៃលោក លោកនឹងទទួលសំណូមពរមួយពីអ្នកនោះ ទោះគេប្រើឲ្យធ្វើការពិបាកយ៉ាងណាក៏ស៊ូតែងតែខំរហូតបានសម្រេចជាស្ថាពរដែរ តើសំដីនេះ

ពិតឬទេ ?

សែហានងីងក្បាលៈ

-មែន ! រឿងនេះអ្នកកុននិយមដឹងគ្រប់គ្នា ។

ហ្វូភទីដពោលបន្ត :

ខាងខ្ញុំឮទៀតថាក្នុងចំណោមបញ្ញាដែកសំរិទ្ធិទាំងបីនោះ លោកបានទទួលពីរបន្ទះវិញហើយ ហើយព្រឹត្តិការណ៍ស្មុគស្មាញដ៏រំជើបរំជួលក៏បានផ្ទុះឡើងពីរដងក្នុងពិភពកុនដែរ ។ រីបញ្ញាដែកសំរិទ្ធិមួយនេះជាបញ្ញាចុងក្រោយបំផុតមែនទេ ?

សែហានទំព្ទនាងក្រមុំបទីប្រយោគ « ...ព្រឹត្តិការណ៍ស្មុគស្មាញដ៏រំជើបរំជួលក៏បានផ្ទុះឡើងពីរដងក្នុងពិភពកុនដែរ... » ក៏ជុះវិកមុខ ។ គាត់ឆ្លើយថា:

- ពិតមែន ! មិត្តដែលបានទទួលបញ្ញាដែកសំរិទ្ធិពីយើងនោះស្លាប់បាត់បង់ជីវិតយូរហើយ ។ គេមានកម្រិតយុទ្ធសិល្បៈខ្ពស់ណាស់ អាចសម្រេចកិច្ចការអ្វីបានដោយខ្លួនឯង មិនចាំបាច់ពឹងយើងទេ ហេតុនេះបញ្ញាដែកសំរិទ្ធិគឺពុំសូវមានប្រយោជន៍ប៉ុន្មានសម្រាប់គេដែរ ។ ក្រោយពេលស្លាប់ទៅដោយគ្មានកូនចៅ បញ្ញាដែកសំរិទ្ធិក៏ធ្លាក់ក្នុងកណ្ដាប់ដៃអ្នកដទៃ ។ ក្នុងរវាងប៉ុន្មាន...នេះ អ្នកកុននិយមខំស្វះស្វែងរកបញ្ញាដែកសំរិទ្ធិគ្រប់ទិសទី ដោយចង់យកមកបញ្ជាឲ្យត្រកូលសែរយើងនេះបំពេញកិច្ចការឲ្យគេ ។ ហ៊ឺះ ! ស្មានមិនដល់ថា ថ្ងៃនេះយើងបានទទួលបន្ទះដែកសំរិទ្ធិដោយផ្ទាល់ដៃនិងងាយស្រួលបែបនេះសោះ ។ យើងនិយាយប្រាប់ឯងឲ្យត្រឹមត្រូវទៅចុះ ការដែលយើងទទួលបញ្ញាដែកសំរិទ្ធិនេះគឺជាការញ៉ាំងអ្នកកុននិយមឲ្យអស់សង្ឃឹមមែនហើយ តែក៏ជាការជួយចម្លងគ្រោះថ្នាក់ឲ្យពួកទាំងនោះដែរ ។

និយាយដល់ត្រង់នេះ គាត់យារជើងទាត់សាកសពក្នុងការវ៉ីហើយពោលបន្ត :

- ទោះគេបានបញ្ញាដែកសំរិទ្ធិហើយក៏ដោយ ក៏...គេជួបយើងបានដូចបំណងដែរ ។ នៅមុខពេលប្រគល់បញ្ញាឲ្យយើង ជនម្ចាស់បន្ទះសំរិទ្ធិត្រូវតែប៉ះនឹងទប់ទល់ នឹងសត្រូវគ្រប់ទិសទី ព្រោះអ្នកកុននិយម នរណាក៏ចង់បានបញ្ញាដែកសំរិទ្ធិដែរ ។ សូម្បីមនុស្សដែលមានកម្រិតវិជ្ជាជ្រៅជ្រះដូចលោកម្ចាស់ភូមិសាច់ស៊ី ក៏នៅតែគេចសពីងមិនរួច ចុះទម្រាំអ្នកក្រៅ. . .ហាស ! ហាស ! . . .

ពាក្យសំដីប៉ុន្មានម៉ាត់ចុងក្រោយ ពោរពេញដោយការចំអកឡកឡឺយ ធ្វើឲ្យស៊ុយ៉ឹងក្រហមត្រដេតក្រៀកដោយក្ដីក្ដៅក្រហាយ ។ គាត់ធ្លាប់មានឈ្មោះល្បីល្បាញសុសសាយពេញពិភពគុនសំដីមួយម៉ាត់ៗ ដែលនិយាយចេញ មិនដែលនរណាហ៊ានជំទាស់ឡើយ តើគួរអីមកត្រូវសែយានទីដុំផ្សែងផ្កាយ៉ាំងនេះ ? វុនយូក៏មានចិត្តគំនិតប្រហែលប្ដីដែរ គាត់ខឹងធ្ងួលហើយលបសង្កេតស៊ុយ៉ីងក្រងីចញ្ចៀញប្រតិកម្មវាយលុកសែយានទី អាលគាត់បានរួមកម្លាំងផង ។ ទោះដឹងថាមិនឈ្នះគេក៏ដោយ ក៏គាត់នៅតែប្រកាន់គំនិតនេះដដែល ។

សែយានទីបន្តយ៉ាងសោះកក្រោះថា :

- លោកប្រុសលោកស្រីស៊ុ ជាអ្នកក្លាហានត្រឹមត្រូវ បើបានបញ្ហាដែកសំរិទ្ធមិនជាអីប៉ុន្មានទេ ជួយទៅវិញលោតែធ្លាក់ក្នុងកណ្ដាប់ដៃជនចោកខាងយង់ឃ្នង គេនឹងប្រើឲ្យយើងកាត់ដៃកាត់ជើង ឬសម្លាប់ខ្លួនឯងពុំខាន ហើយបើយើងមិនព្រម, មិនខុសនឹងពាក្យសន្យា ? តែជាសំណាងល្អ យើងបានទទួលមកវិញ ដោយងាយដូច្នេះ.... ហាស ! ហាស !..

គាត់សើចក្អាកក្អាយ ឡើងខ្ទ័រក្បៀងដំបូលផ្ទះ ។

ហួរ៉ន់ដី នៅក្មេងខ្ចីមែន តែក្លាហានអង់អាចណាស់ ។ នាងបន្ទីវថា :

- លោកសែបានសន្យាថា ប្រសិនបើបានទទួលបន្ទះដែកសំរិទ្ធពីជនណាម្នាក់ លោកនឹងចំបំពេញសំណូមពរជននោះលុះត្រាសម្រេចដូចបំណង ទោះជននោះជាសត្រូវស្លូតក៏ដោយ !

នាងក្រមុំពោលដល់ត្រឹមណោះក៏អាក់សំដីព្រោះសមាជិកដំរកាំបិតមាសដូចជាហ្វុងជីខ្វ, អ្នកស៊ុមូរុងនិងចូវមុ ទើបនឹងមកដល់បន្តបន្ទាប់គ្នា ។

នារីបន្ត:

- របញ្ហាដែកសំរិទ្ធលោកបានទទួលពីដៃប្អូនប្រុសនេះ ម៉េចក៏ប្អូនប្រុសគ្មានសិទ្ធិលើកយកបញ្ហាមួយមកឲ្យលោកជួយដោះស្រាយ ?

សែយានទីគ្រហឹម ហុះ! តប:

- អាកូនស្នូមនេះជាស្អីទៅ បានជាគម្រូវឲ្យយើងសែយានទីស្ដាប់បង្គាប់វា ? ហាស ! ហាស! ធ្វើដូច្នេះ មិនខ្លាចអ្នកផងគេសើចយំទេឬ ?

ហួរ៉ន់ដីស្រែកខ្លាំងៗ:

– មិត្តទាំងអស់សូមស្តាប់មើលចុះ! លោកសែនិយាយថា ប្អូននេះមិនមែនកូនមនុស្សទេ ម្លោះហើយពាក្យសច្ចៈរបស់គាត់ក៏គ្មានន័យឬតម្លៃអ្វីសម្រាប់គ្នាដែរ!

សែយានទីថ្លោះទឹកមុខ និកថា «មេក្មេងចង្រៃនេះញុះញង់ឲ្យគេប្រមាថអញហើយតើ ហើយកាកូនសូមក៏ប្រែហែលជាអន្ទាក់របស់វាដែរ ។ អញបានទទួលបញ្ហាដែកសំរិទ្ធពីអាល្អិតនេះហើយបើងប្រគល់ឲ្យវាវិញក៏មិនកើត ...» ។ គិតដូច្នេះ គាត់របេកូពិនិត្យមើលជុំវិញ ឃើញក្រៅពួកស៊ីឈើងនៅមានអ្នកគុននិយមជាច្រើន ។ គាត់សើចក្អាកក្អាយពោលថា:

– កូនលោកនេះ តើមានកិច្ចការណាខ្លះដែលធ្វើឲ្យយើងខាតព្រួក? នែអាល្អិតឯងមកតាមអញ! បើមានសំណូមពរអ្វីសុំឲ្យអញជួយ យើងទៅនិយាយគ្នាកន្លែងផ្សេងកុំឲ្យខាតពេលអ្នកក្រៅ ។

ពោលចប់គាត់ដឹកដៃកូនសូមប្រុងចេញដំណើរ ។ គួរបញ្ជាក់ថាសែយានទី មិនខ្លាចអ្នកគុននិយមទាំងនេះទេ តែគាត់បារម្ភក្រែងពួកនេះបះញុះកូនសូមឲ្យចេញបញ្ហាដ៏ពិបាក ដើម្បីធ្វើបាបគាត់ដូចជាបញ្ហាឲ្យកាត់ដៃកាត់ជើងឬសម្លាប់ខ្លួនជាដើម ។ ដូច្នេះទើបគាត់ប្រញាប់នាំសូមល្អិតទៅរកកន្លែងស្ងាត់ដើម្បីសាកសួរឲ្យបានល្អិតល្អន់ ។

ហ្លួវាន់ជីស្ទុះទៅមុខ ពោលល្អួងលោម:

– អូនប្រុស! អូនជាក្មេងដ៏ល្អប្រសើរ រីលោកអាំខាងណោះចូលចិត្តសម្លាប់មនុស្សណាស់ ហេតុនេះអូនឆាប់អង្វរគាត់ឲ្យឈប់កាប់ពឃាតមនុស្សចាប់តាំងពី ...

និយាយមិនទាន់ចប់ផង ស្រាប់តែមានកម្លាំងខ្យល់បក់វិលម្រង់មកធ្វើឲ្យនាងហាមាត់ទៀតលែងរួច ។

ដ្បិតហ្លួវាន់ជីវៃឆ្លាតណាស់ នាងដឹងថាសែយានទីមិនក្បត់ពាក្យសច្ចៈរបស់ខ្លួនទេ ម្លោះហើយនាងឆ្លៀតល្អួងលោមកូនសូមឲ្យចេញបញ្ជាហាមប្រាមគាត់ឲ្យឈប់សម្លាប់មនុស្ស ចាប់ពីថ្ងៃនេះតទៅដើម្បីស្រោចស្រង់ខ្លួនឯងនិងបងប្រុសគ្រូឲ្យផុតពីគ្រោះភ័យ ។ ព្រោះអម្បាញ់មិញក្នុងចំណោមសិស្សក្នុងទឹកកកទាំងប្រាំពីរ មានវូងវាន់យីម្នាក់គត់ដែលរួចខ្លួនក្រៅពីនេះសុទ្ធតែជាប់គាត់ម្នាក់ៗមួយដាវ ។

ហេតុនេះទើបនាងក្រប៉ុតាំងចិត្តប្តូរផ្តាច់កគ្រប់មធ្យោបាយ ទាល់តែមិនឲ្យសែយានទីតាមសងសឹករូបនាង និងបងប្រុសគ្រូទាំងប្រាំនាក់ ។ ប៉ុន្តែដង្ហក្រក្លស់សែយលប់រាវនាងច្បាស់ណាស់ ទើបប្តូម្ចាស់លោកសំដែងអាវបញ្ចេញកម្លាំងខ្យល់ដ៏ខ្លាំងក្លា ធ្វើឲ្យសិស្សក្នុងទឹកកកចាប់ផ្តើមគិងឡូវរកបញ្ជាប់ប្រយោគ

មិនទាន់ គាត់គំហក :

- តាឯងនៅទីនាទៅយើងដល់ណាទៀត ?

ឯតាគ្រមុំចាប់កម្លាំងខ្យល់ដៃមិនរួចក៏ដួលប្រូសៈភាដី ។ ហួរាំងផីប្រញាប់ស្ទុះក្រោកឈរវិញ ប្រុងស្រែកហៅតែហួសពេលស្រេច សេះយានទីចាំទូងស្ទូមបត់បែនបាំងមីងផញ្ចាំងផ្ទះ បាត់ស្រមោលទៅហើយ ។ ចំណែកអ្នកឯទៀតសុទ្ធតែញញើតញញើមនឹងជនត្រកូលសេ ទើបគ្មាននរណាហ៊ានឃាត់ឃាំងគាត់ ។ ស៊ុយឈីងចេះដំហានទៅមុខ លើកដៃគោរពចិនវ៉ាន់ជុង មិនវុនភិនយី បន្ទរថា :

- ប្អូនចិននិងលោកបងវុន, ប្អូនស្រីវាងពេះត្វាហាងអង់អាចណាស់ ហេតុនេះហើយទើបគេដាក់ឈ្មោះឲ្យថា «នារីផ្កាកុលាប» មែនទេ? ចំណែកបងប្អូនម្នាក់ទៀតនេះ សូមអភ័យទោសខ្ញុំមិនស្គាល់ទេ សូមប្អូនចិនជួយណែនាំផង ។

ចិនវ៉ាន់ជុងមានមាឌធំ, តាយតប :

- បានជួបលោកមេភូមិនៅទីនេះប្រសើរណាស់ សោះនឹងធ្វើដំណើរទៅរកដល់ភូមិសាំនស៊ូ

ស៊ុយឈីងឃើញទឹកមុខអ្នកទាំងប្រាំពីរមិនសូវស្រួល គាត់ស្មានថាមកពីចាញ់ប្រៀបសេះយានទី ទើបពួកគេមិនសប្បាយចិត្ត ។ តែមកនឹកឆ្ងល់នឹងចិនវ៉ាន់ជុងដែលធ្លាប់មានការទាក់ទងគ្នា ហេតុអ្វីធ្វើពុកពាព្រងើយកន្តើយម្ល៉េះ ? ពីមុននាយធ្លាប់ហៅគាត់លោកបងស៊ុ ពេញមាត់ ឥឡូវម៉េចងាប់កែសំដីម៉្លេះ ? គិតចុះគិតឡើងភ្ញាក់ព្រើត «អូ ! ប្រហែលកូនប្រុសយើងធ្វើអ្វីខុសទៀតហើយ ! » នឹកដល់ត្រង់ណោះ គាត់ពោលថា :

- លោកប្អូនចិន ! តើកូនខ្ញុំវាធ្វើអ្វីឲ្យលោកប្អូនតាស់ចិត្តឬ? ប្តីប្រពន្ធខ្ញុំសូមអភ័យទោស[illegible] សូមអញ្ជើញបងប្អូនទាំងអស់ទៅផឹកតែលៀងឲ្យសប្បាយម្តង

តានហ្វុងយី ឃើញស៊ុយឈីងគួរសមរាក់ទាក់នឹងសិស្សគំរូភក្តកតែពួកគេបិទះអំពើសោះ គាត់ខឹងក្រៃ តែមកនឹកថាជារឿងផ្ទាល់របស់គេមិនត្រូវលូកលាន់ទេ ។ គាត់បែរទៅរកស៊ុយឈីងនិងវុនយូ:

- លោកម្ចាស់ភូមិនិងលោកស្រី, ខ្ញុំសូមលាសិនហើយ ។

ស៊ុយឈីងគោរពតប :

- លោកមេជំរំអាន សូមអភ័យទោស ។ រល់តែសួររឿងកូនប្រុសឈ្មោះស៊ីជុងយីដែលទៅ

រៀនវិជ្ជាយុទ្ធសិល្បៈ នឹងលោកបងហុង ខាងក្នុងកកក ក្មេងគួរសមនឹងលោកបងឡេឈិង ។

តានហុងយីស្ដាប់ឮដូច្នោះ, នឹកថា : «ទុ ! អញ្ចឹងទេតើ, រឿងនេះមិនគួរបន្ទោសគាត់ទេ» គាត់មិនបញ្ចេញស្ដី ម្ចាស់នាំពួកសេនាចេញដំណើរយ៉ាងរួសរាន់ ។ ចំណែកបងប្អូន ទិនភិនជុង ស្រៀមស្ងាត់ដដែល គេចាំពួកកាំបិតមាសទៅឆ្ងាយ ទើបងាកសម្លឹងមុខគ្នាឡើងឡង់, អេះអុញនេះ បញ្ចេញភាពក្រេវក្រោធនិងធុញទ្រាន់ចំពោះរឿងអ្វីមួយ ។

ពាក្យបាស់ថា «មានតែឪពុកទេ ដែលស្គាល់ចរិតកូនខាងគេ» យ៉ាងណាមិញស៊ីឈីង ដូច្នេះដែរ គាត់ដឹងខ្លួនគ្មានលទ្ធភាពក្នុងការប្រៀនប្រដៅកូនកំហូច ក៏ដាច់ចិត្តបញ្ជូនវាឲ្យទៅហាត់រៀ ពីលោកហុងវាន់លី សិស្សជំនាន់ទីពីរនៃក្រុមក្នុងកកក ។

គិតដល់ចរិយាកូនពេលណា ព្រួយពេលនោះ តែទំសម្រួលទឹកមុខ ហើយញញឹម

–លោកពូប្រុស-ស្រីសុខសប្បាយជាទេឬ ? ចុះលោកបងហុងយ៉ាងណាដែរ ?

វុនភាន់យី ចិត្តខ្លាំងជាងគេ ។ នាយស្រែកក្ដែងៗ :

– លោកគ្រូអ្នកគ្រូមិនសម្លាប់អាកូន . . . អាកូន . . . ជាសំណាងល្អហើយ !

នាយបន្ថា «អាកូនឥតពូជ» តែក្រឡេកឃើញឫកពាខនក្ងន់ និង ម៉ឺងម៉ាត់របស់វុនយូ សង្កត់ចិត្តថា តែ «អាកូនៗ» ប៉ុណ្ណោះ ។ ទោះបីយ៉ាងនេះ ក៏ប្ដីប្រពន្ធម្ចាស់ភូមិសាំនស៊ីង កាត់យល់ថា គេបង់ដេរកូនខ្លួនដែរ ។

វុនយូក្រហមក្អែក សួរ :

– លោកបងវុន កូនខ្ញុំបានប្រព្រឹត្តអ្វីខ្លះ ? លោកបងកល់គ្នា ខ្ញុំ... ខ្ញុំ... សូម ដំនួសវាផង ។

ពោលហើយ គាត់បន្ទន់ខ្លួនគោរពសិស្សក្នុងកកកគ្រប់ៗ គ្នា ។ ពួកនេះគោរពតប ហើយវុនភាន់យីស្រែកខ្លាំងៗ :

–អ្នកបងស៊ីត . . . អាកូន . . . របស់អ្នកបងនោះដូចជាជ្រុលបន្តិចហើយ ! មិនបាន តែមានកិរិយាដូចលោកបងអ្នកបងខ្លះទៅ តែនេះទំនេរស្មោះ! បើវាធ្វើឲ្យខ្ញុំម្នាក់ខាសចិត្តមិនអីទេ គ្រា ចាប់វាមកប្រៀនប្រដៅខ្លះទៅរួចគ្នាស្រេច ។ តែមិនអីចឹង វាធ្វើឲ្យលោកគ្រូអ្នកគ្រូពិបាកចិត្ត ខ្លាំង ! លោកស៊ី,មិនមែនខ្ញុំចង់ក្បត់បងប្អូនឯងទេ តែសូមជំរាបថាបងប៉ាយខ្ញុំប្រុងទៅជុំកកំទេពកូ

លោកឯងជាងណាស់ហើយ! គួរ ... គួរបងទាំងពីរចៀសចេញឲ្យឆ្ងាយ . . . ហើយរឿងដប់លៀន នោះខ្ញុំមិនហ៊ានទទួលទេ ...បើបងប៉ាយជីងគាត់ . . . គាត់ឡូស៊ជាកាត់កាល់ខ្ញុំហោលមិនខាន !

នាយពោលរអ៊ូរទាំរៀបរាប់យ៉ាងវែងអន្លាយ តែនៅពុំទាន់បញ្ជាក់កំហុសរបស់ស៊ីជុនយីទេ ។ ប្តីប្រពន្ធស៊ីឈីងរឹតតែស្អាប់ កាន់តែភ័យស្លន់ខ្វះរវេង ហើយព្រមគ្នានេះក៏នឹកឆ្ងល់:

– យើងនិងក្រុមភ្នំទឹកកករាប់អានគ្នាយូរណាស់មកហើយ តើហេតុអ្វីប៉ាយកាន់សានចឹងដាច់ក្បាលដាច់កន្ទុយ រហូតដល់ចង់ផុតបំផ្លាញលំនៅស្ថានយើង ?

ទោះគិតដូច្នេះក៏ប្តីប្រពន្ធស៊ីឈីងមិនហ៊ានសួរភ្លាមដែរ ។ ស៊ីឈីងបន្ទោសកូនថា:

– អាកូនចង្រៃនោះថ្មើមធំអស្ចារ្យ ហ៊ានដល់ទៅធ្វើឲ្យអំប្រុស-ស្រីតាស់ចិត្តផង ?

ខិនរ៉ាន់ជុងបេះគិតវែងឆ្ងាយ ពោលថា :

– ទីនេះមិនមែនជាកន្លែងសម្រាប់ជជែកគ្នាទេ គួររកគ្រឹះណាឲ្យបានសមរម្យបន្តិច ។

ពោលហើយ ដើរនាំផ្លូវទៅមុខដោយបន្ទាន់ថា :

– សូមលោកប្រុសលោកស្រីអញ្ជើញ !

ដើរមួយសន្ទុះ គេប្រទះម្លប់ឈើមួយដ៏ត្រឈឹងត្រឈៃ ។

ខិនរ៉ាន់ជុងស្នើ :

– យើងអាចនិយាយគ្នាត្រង់នេះបាន ។

ពេលអ្នកទាំងអស់គ្នា រកកន្លែងអង្គុយ បានស្រួលបួលហើយ រ៉ាន់ជុងណែនាំសិស្សម្ដងម្នាក់ឲ្យស៊ីឈីងស្គាល់ ។

សិស្សម្នាក់ផ្តើម:

– លោកមេក្លូមិស៊ី យើងទើបស្គាល់គ្នាជាលើកដំបូង ខ្ញុំមានយោបល់មួយមិនសូវសមគួរចង់ស្នើ តែបើនិយាយហើយ សូមកុំប្រកាន់ណា ។ តាមយោបល់របស់ខ្ញុំ លោកបងគួរប្រគល់កូនឲ្យពួកខ្ញុំនាំរ៉ាត្រឡប់ទៅភ្នំវិញ ក្រែងរកបជួយអង្វរករសុំទុកជីវិតឲ្យរ៉ាបានខ្លះ ។ ប្រសិនបើលោកគ្រូអ្នកត្រូវសុខចិត្តសម្រាលទោសខ្លះ ដោយគ្រាន់តែលាយយុទ្ធសិល្បៈរ៉ាចោលនោះ ខ្ញុំយល់ថាជាមធ្យោបាយមួយដ៏ប្រសើរ ព្រោះភ្លូមិសានស៊ូនិងក្រុមភ្នំទឹកកកនឹងមិនទៅជាសត្រូវនឹងគ្នាទេ !

ស៊ីឈីងសួរទាំងឆ្ងល់ :

- តាំងពីខ្ញុំបញ្ជូនកូនប្រុសទៅក្រុមអស់លោក ពេលវេលាកន្លងទៅបីឆ្នាំហើយ , ខ្ញុំមិនដែល បានជួបមុខវា ឬ បានដំណឹងអ្វីសោះទេ , តើមានរឿងអ្វីកើតឡើងខ្លះ សូមលោកមេត្តាកុំលាក់ខ្ញុំ

វិនកាន់ជុងសួរបញ្ជាក់ :

- លោកម្ចាស់គូមិញ្ញនពិតជាមិនដឹងមែនឬ ?

ស៊ីឈីងងក់ក្បាលពោលយ៉ាងម៉ឺងម៉ាត់ :

- មែន !

វិនកាន់ជុងភ្ញាក់ស្គាល់ចិត្តថ្មើម ស៊ីឈីងដែលនិយាយម៉ាត់ណាម៉ាត់ហ្នឹង ក៏ពោល:

- មកពីលោកឥតប្រាប់រឿងហេតុបានជាអ៊ីចឹង ។

វ៉ុនយូព្រួយកូនប្រុសពេកក្រាំពុំបានសួរគាត់ថា:

- កូនយើងខ្ញុំមិននៅក្នុងទឹកកកទេឬ ?

វិនកាន់ជុងងក់ក្បាល ។ វ៉ុនកាន់យីឆ្លើយ :

-បើអាចង្រៃនោះនៅក្នុងទឹកកក នោះវាមានជីវិត ១០០ ក៏មិនសល់ឆ្អឹងដែរ ។

ស៊ីឈីងឮដូច្នេះ រឹងឆ្ងល់ នឹកថា :

- យើងបញ្ជូនកូនទៅរៀនយុទ្ធសិល្បៈពីពួកឯង មកពីយើងគោរពសរសើរឯងថាពូកែចំណាប់ហើយ តើ ម្ដេចពួកឯងមិនចេះយោគយល់ក្មេងអប់រំវាឲ្យចេះស្គាល់ច្បាប់ទម្លាប់ផង ។ ទោះបីវាខិល ខូចយ៉ាងណាក៏ដោយ ឯងមិនត្រូវសម្លាប់វាដូចសត្វធាតុទេ ។ ធ្វើបែបនេះយើងចាត់ពួកឯង ជាមនុស្សឃោរឃៅលោកលើក្មេង, ជាមនុស្សផ្ទុយជាតិឥតស្គាល់ច្បាប់ទៅវិញទេ ។

ស៊ីឈីងខឹងណែនទ្រូង តែគាត់ទប់ក្បាលទឹកមុខពោលធ្វើហី :

- ខ្ញុំដឹងហើយថា ក្រុមបក្សលោកមានវិន័យតឹងតែងណាស់ , ព្រោះហេតុចង់ឲ្យកូនប្រុសខ្ញុំ ក្លាយជាអ្នកក្លាហានល្បីល្បាញ ទើបខ្ញុំបញ្ជូនវាទៅរៀនទីនោះណា !

វិនកាន់ជុងទម្លាក់ទឹកមុខពោលតប :

- លោកម្ចាស់គូមិមានប្រុសសទ៍ដូចជាជ្រុលពេកហើយ កែស៊ីជុងយើងមានថ្ងៃមពាសមេឃ ហើយ ប្រព្រឹត្តអំពើឃោរឃៅបែបនេះ មិនមែនវារៀនពីពុកខ្ញុំទេ , សូមលោកប្រាប់ឲ្យច្បាស់ ។

ស៊ីឈីងសួរបែបហីទៀត :

– សំដីដែលថាធ្វើមពាសមេឃ...អំពើឃោរឃៅមានន័យយ៉ាងណាដែរ ?

ចិនភន់ដុងថែរទៅប្រាប់ហ្លួកន់ដីថា :

– អូនស្រី, សូមទៅមើលខាងក្រៅយាមកុំឲ្យអ្នកក្រៅចូលមកខាងយើង ។

ហ្លួកន់ដីឆ្លើយថា:បា ក៏នាងដើរចេញទៅ, ស៊ុឈីងនិងភរិយាងាកមើលមុខគ្នានឹកថាគេដេញហ្លួកន់ដីទៅឆ្ងាយប្រហែលមានពាក្យសំដីដែលមិនគួរនិយាយចំពោះមុខស្រីៗឬ ?

ពេលនោះចិនភន់ដុងដកដង្ហើមធំ:

– លោកម្ចាស់ក្រុមហ្លួងប្រហែលជ្រាបដែរថា លោកយាយប៉ាយខ្ញុំគ្មានកូនប្រុសទេ មានតែកូនស្រីមួយគ្រាប់ដែលគាត់ស្រឡាញ់ថ្នាក់ថ្នមដូចពេជ្រពន្លក ។ នាងតូចក្មួយខ្ញុំនោះមានអាយុ១៤ឆ្នាំហើយ ឆ្លាតវាងវៃស្រស់ប្រិមប្រិយគួរឲ្យស្រឡាញ់ណាស់, មិនថាត្រឹមលោកបងប៉ាយទេ សូម្បីតែលោកគ្រូនិងអ្នកគ្រូក៏ស្រឡាញ់នាងដូចកែវភ្នែកដែរ ។ ក្មួយស្រីខ្ញុំអាចប្រៀបប្រដូចនឹងកូនស្តេច នៅក្នុងប្រាសាទទឹកកកភ្លឺថ្លាដូចកញ្ចក់ណា ! ព្រោះហើយគ្មាននរណាហ៊ានធ្វើឲ្យប៉ះពាល់កូនចិត្តនាងសូម្បីបន្តិចទេ ។

ស៊ុឈីងស្តាប់ដល់នេះងក់ក្បាលមួយៗ សួរទៀត :

– ប្រហែលអាកូនចង្រៃខ្ញុំវាធ្វើអីប៉ះកូនចិត្តម្ចាស់ក្សត្រីក្នុងប្រាសាទទឹកកកឬ ?

–ទេ ! ពាក្យថាធ្វើឲ្យពាល់ចិត្តដូចជាស្រាលណាស់ កូនប្រុសលោកធ្វើមធំ ត្រង់ហ៊ានចាប់ក្មួយស្រីយើងចងដៃចងជើង ហើយសំរាតខោអាវអស់រលីង គឺវាចង់រំលោភកាយក្មួយស្រីតូចយើងណា !

ស៊ុឈីងនិងវុនយូដាក់ភរិយាភ្ញាក់ក្រញាំងណាន់មាត់ព្រឺព្រួ ក្រោកឈរភ្លាមៗ វុនយូមានទឹកមុខសស្លាំងដូចក្រដាស, ស៊ុឈីងសួរ:

–ពិត.. ជាមានរឿងដូចនេះមែនឬ ? ជុងយីទើប...អាយុ១៥ឆ្នាំទេតើ ? ប្រហែលជាមានការភ័ន្តច្រឡំទេដឹង ?

– មុនដំបូងពួកខ្ញុំមិនជឿទេ, តែបំរើពីរនាក់ដែលចំណាំដើរតាមក្មួយស្រីខ្ញុំនោះឃើញជាក់ស្តែងៗ លោក ! ស្រីបំរើម្នាក់ឮនាងតូចស្រែក ក៏រត់ទៅមើលឃើញច្បាស់ថាអាជុងយី វាស្រែកហៅគេជួយផ្អើលអស់មនុស្សមួយក្រុម ។ យី ! អស្ចារ្យណាស់ អាយុ១៥ឆ្នាំមែន តែហ៊ានកាប់ស្រីបំរើម្នាក់ដាច់ដៃម្ខាង, ម្នាក់ទៀតដាច់ជើងសន្លប់បាត់ស្មារតី ហើយលែងប៉ះប្រាណក្មួយស្រីយើង រត់បោលក្នុង

បាត់ស្រមោលតាំងពីថ្ងៃនោះមក ។

នៅក្នុងពិភពគុកមានច្រណាមតឹងរ៉ឹងជាងគេ គឺហាមសិស្សគណមិនឲ្យប្រព្រឹត្តអំពើអនាចារទាបថោក ដូចរំលោភព្រហ្មចារីនារីជាដើម ។ អំពើឯទៀតនោះសាហាវយង់ឃ្នងបែបណាក៏គេមិនសូវប្រកាន់ទោសដែរ ។ វុនយូក័យស្ងាំងមុខទាញដៃភាវប្តីសួរតិច ៗ :

- យើង ... យើងគិតធ្វើម៉េចទៅ ?

ស៊ីឈីងជ្រួលច្របល់យ៉ាងខ្លាំង ព្រោះគាត់ជាមនុស្សសច្ចៈ យុត្តិធម៌ស្អាតល្អណាស់ , បើកូនប្រព្រឹត្តអំពើទាបថោកបែបនេះគាត់ត្រូវចេញមុខទទួលទោស តើគាត់លំបាកចិត្តយ៉ាងណា បើមិនដឹងមិនឃើញផ្ទាល់ភ្នែក ? បើកូនប្រុសនៅជិតនេះគាត់សម្លាប់វាចោលភ្លាម ។

ស៊ីឈីងតាំងចិត្តរឹងប៉ឹងពោល :

- ទេវតាលោកជួយហើយ បានជានាងតូចក្មួយអស់លោកនៅបរិសុទ្ធដដែល ។ ស្តាយណាស់ដោយកូនឧក្សាតមិននៅជិតខ្ញុំ ! កុំអីខ្ញុំសម្រេះវាជូនអស់លោកមើលភ្លាម ។

ទិនវ៉ាន់ជុងគ្រវីក្បាលពោលបន្ត :

- ក្មួយស្រីនៅបរិសុទ្ធមែន ប៉ុន្តែលោកស្គាល់ចិត្តលោកគ្រូខ្ញុំស្រាប់ហើយ គាត់មិនដែលអត់ធន់ទោសបែបនេះទេ ។ លោកគ្រូយោគយល់លោកម្ចាស់ក្មួយណាស់ បានជាលោកចេញបញ្ជាឲ្យតាមរកស៊ុជុងយីជាបន្ទាន់ព្រមទាំងផ្តាំថា កាលណាឃើញវាត្រូវសម្លាប់ចោលភ្លាមមិនបាច់នាំវាទៅប្រគល់ជូនគាត់ទេ ។

វុនវ៉ាន់យីពោលបន្ត :

- លោកគ្រូមានប្រសាសន៍ថាគាត់ធ្លាប់ទាក់ទងជាមួយលោកបែបហ្នឹង គាត់លើកដៃប្រហារកាជុងយីមិនកើតទេ . . .

ទិនវ៉ាន់ជុងងាកមកសម្លក់គាត់ថ្នាំហាក់បន្ទោសថាគាត់និយាយហួសព្រំដែន ។ វុនវ៉ាន់យីឃើញដែរតែគាត់សួរបញ្ជាក់ថា:

- លោកគ្រូមានប្រសាសន៍អ៊ីចឹងមែនណា ! ខ្ញុំនិយាយខុសត្រង់ណាឬ ?

ទិនវ៉ាន់ជុងហួសចិត្តជំរំណាលរឿងគំរែងខ្ញុំរវល់និងវ៉ាន់យី:

- អារឿងកាប់ដៃ និងដេកស្រីបំរើពីរនាក់បងធ្ងន់ប៉ុន្មានទេ , រឿងធំស្ទើតនៅត្រង់ក្មួយស្រីយើង

ខ្ញុំតោះឯង ! នាងនៅក្មេងចិត្តខ្លាំងមិនសូវពិចារណាវែងឆ្ងាយ គ្រាន់តែត្រូវគេប្រមាថប៉ុណ្ណោះក្លាម ខឹង យល់ច្រឡំថា សេរីមិនកើតទៀតទេ គោងសម្លាប់ខ្លួនលាពិភពលោកទើបប្រសើរ ម្ល៉ោះហើយនាងយំសោកបោកខ្លួនពីរថ្ងៃបីយប់ រហូតដល់រាត្រីទីបី ទើបនាងលបលោតតាមបង្អួចទម្លាក់ខ្លួនក្នុងជ្រោះជ្រៅស្លាប់ទៅ ! ហ៊ឺ ! ...អស្ចារ្យណាស់ ។

ស៊ីឈីននិងវុនយូស្រែកយំ ! ព្រមគ្នា ។ ស៊ីឈីនសួរ:

-តើ . . . មាននរណាជួយទាន់ទេ?

ទិនភន់ឌុងគ្រវីក្បាល:

-លោកជ្រាបស្រាប់ហើយជ្រោះនៅក្រោមប្រាសាទទឹកកកនោះជ្រៅមើលមិនឃើញបាតទេ កុំថាឡើយត្រឹមក្មេងតូចសាច់ខ្ចីឆ្អឹងទន់, សូម្បីដុំថ្មក៏បែកខ្ទេចដែរ . . . តើមានសង្ឃឹមត្រង់ណា ?

សិស្សក្នុងទឹកកកម្នាក់ក្មេងជាងគេឈ្មោះទិភន់ផនស្រែកទាំងកំហឹងថា:

-គួរអាណិតបងហ្វុងណាស់; មិនគួរលោកគ្រូកាប់ដៃម្ខាងដោយឥតហេតុផលសោះ !

ស៊ីឈីនភ្ញាក់ផ្អើល :

- លោកតាតក្វើនហ្វុងភន់លីឬ?

ទិនភន់ឌុងឆ្លើយ :

- មែនហើយ ! លោកគ្រូយើងខ្ញុំស្រឡាញ់ចៅស្រីណាស់ កាលបើរកមកចៅលោកមិនឃើញ គាត់ខឹងក្រេវក្រោធស្តីបន្ទោសលោកបងហ្វុងថា មិនចេះប្រដៅប្រដៅសិស្ស ។ គាត់ជេរណាស់ រកតែខឹងណាស់ មិនដឹងធ្វើម៉េចស្រាប់តែស្រាចកំហឹងលើលោកបង ដោយហូតដាវពីចង្កេះកាត់ដៃបងហ្វុងដាច់បាត់ ហ៊ឺ!លោកបងហ្វុងមានវិជ្ជាខ្ពង់ខ្ពស់ដល់ណាក៏អស់ថ្វីមសារដែរ គ្រោះគាត់ក្លាយជាមនុស្សពិការទៅហើយ ។ បន្ទាប់ពីនោះអ្នកគ្រូបន្ទោសលោកគ្រូមួយម៉ាត់ពីរ កើតទៅជាប្រកែកគ្នាតឹងសរសៃកនៅចំពោះមុខសិស្សទាំងអស់ ។ ដដែកគ្នាខ្លាំងឡើងលោកគ្រូមិនដឹងនឹកឃើញយ៉ាងម៉េច ស្រាប់តែយារដៃទះកំផ្លៀងអ្នកគ្រូផាំង ! អ្នកគ្រូខឹងប្រឡេតស្ទុះហោះចេញទៅដោយពោលពាក្យផ្ដាំផ្ញើថា បើគាត់មកជាន់ដីក្នុងទឹកកកទៀត គាត់មិនធ្វើមនុស្សឡើយ ។

ស៊ីឈីន ស្ដាប់យូរទៅរកតែគៀនខ្លាស, រកតែខឹងក្រហាមមុខ និកថា:

- យើងធ្លាប់ស្ញើចសរសើរវិជ្ជាគុនដាវរបស់ហ្វុងភន់លី ដែលរហ័សមិនខ្លាំងប្រៀបដូចសន្ទឹកខ្យល់

ពិណាចទើបបញ្ជូនកូនប្រុសឲ្យទៅរៀនពីគេ ។ ឥឡូវនាំទុក្ខទោសឲ្យគេវិញគួរអាម៉ាស់មុ
គិតខ្មាសអ្នកគុននិយមខ្លួនទៅណាស់ ។ ហ្វុងវាន់លី មានសត្រូវច្រើន , កាលបើក្លាយ
ជនពិការហើយ គាត់ច្បាស់ជាមិនហ៊ានឃ្លាតចេញពីក្នុងទីក្រុងឡើយ ។ តើយើងបានគុតបស្នងស
គុណគេហ្ន៎ ?

ខណៈនោះវុនវាន់យីពោលបន្ត:

-លោកប្អូនវិភាគណាតែបងហ្វុងមិនអាសូរលោកបងប៉ាយខ្វះទេឬ? ហ៊ឺ ... កូនស្រីព
ស្លាប់ពេលអសារផតការ ... ប្រពន្ធវង្វេងស្មារតី ...

ស៊ីឈីងនិងវុនយូក៏យកក់ស្គុតផងខ្មាសអៀនផងចង់មុជក្បាលចូលក្រោមដី កុំឲ្យគេឃើញមុខ
បើកូនប្រុសគាត់មិនកំបាត់ម៉េះវាដើរបន្តទុក្ខទោសបំពេញមុខម្តាយឪពុកយ៉ាងណាទៅ ?

ស៊ីឈីងនៅតែទំស្ងួរ:

-បងស្រីកើតតែបានជាវង្វេងស្មារតី ?

- យ៉ាមេចលោកឆ្ងល់ មានតែអាកូនសំណប់លោកមួយនោះណ៎ា ! គ្រាន់តែក្មួយស្រីស្លា
បងស្រីយំសោកបោកខ្លួនស្តាយកូនបណ្តូលចិត្តក្អួតបាយទឹកទៅហើយ , ដល់បងប៉ាយ
បន្ទោសគាត់ថា មិនមើលថែរក្សាកូនទៀត គាត់ត្រឡប់ជាស្រែកយំពោលថ្កូវ:

- អាស៊ុវអើយ អាស៊ុវ ! ម្តាយសម្លាប់កូនហើយ ! កូនមាសម្តាយអើយ ! ស្លាប់ដោយស
ម្តាយ ..

តាំងពីថ្ងៃនោះមក គាត់វង្វេងវង្វាន់ពោលតែពាក្យដដែល ៗ ទាល់តែចាត់បងស្រីពីនោះគាត់
រក្សាតាំងយប់តាំងថ្ងៃទើបគាត់មិនសម្លាប់ខ្លួនតាមកូនស្រី ។ ឥឡូវនេះលោកបងប៉ាយបន់ទៅអ្នក
បានស៊ិនស៊ូឲ្យខ្លួនទៅជាផេះណ៎ា ! លោកគិតមើលសមទេ ?

ស៊ីឈីងងើយក្បាល:

-សមណាស់ ! ពីនាក់ប្តីប្រពន្ធខ្ញុំនេះខ្មាសគេអស់មុខមនុស្ស មិនអាចនៅស្ងៀមបានឡើយ
ខ្ញុំដើរស្វែងរកឃាតករថ្មានោះឲ្យទាល់តែឃើញ អ្នកសរវាទៅក្នុងទីក្រុងសម្លាប់សែនខ្ទុំនាំងក្តបំពេញ
អស់លោកមិនខាន ។

អ្នកស្រីវុនទ្រូហោយំបោកខ្លួនលើគ្រែស្ទើរស្លាប់សន្លប់បាត់ស្មារតី ។ ស៊ីឈីងចាប់គ្រូបានបង

និយាយយ៉ាងរហ័ស   បួយសន្ទុះនាំទើបវុនយូ ងើបខ្លួនវិញ ។ វុនកាន់យី ពោលថា :

-លោកម្ចាស់ក្លួបំភ្លេចជីវិតគ្នាយើងពីរនាក់ទៀតហើយ. គោងរាប់បញ្ចូលក្នុងញ៉ឹផង ។

ស៊ុយឈីងភ្ញាក់ព្រើតសួរ :

-មានពីរនាក់ទៀតស្លាប់ដែរឬ ?

ស៊ុយឈីងពោលខ្សាវៗ ដោយអំណាចអៀនខ្មាសនិងតក់ស្លុតចំពោះដំណឹងអកុសល ។ គាត់ធ្លាប់ឃើញគាត់ប្រយុទ្ធបង្ហូរឈាមគ្រប់បែបយ៉ាង ហើយធ្លាប់ឃើញសត្រូវស្លាប់កួនបង្កើតនៅចំពោះមុខទៀត តែគាត់មិនដែលតារណាចគាត់មដូចពេលនេះឡើយ ។ ចំពោះម្ចាស់ក្លួមិបានហ៊ានស៊ូការឈឺចាប់ខាងផ្លូវកាយឬផ្លូវចិត្ត មិនធ្ងន់ដល់ការខ្មាសគេ និងអំពើបាបកាកបស់កូនប្រុសឈ្មោះស៊ុផុងយីទេ ។

វុនកាន់យីពោល :

- ក្រោយពេលកើតហេតុនោះ លោកគ្រូចាត់សិស្ស ១៨ នាក់ទៅជាមួយបងប៉ាយផុតបំផ្លាញក្ដួមបានសិនស៊ូរបស់លោកនៅជាងណានហើយថា...ថា...

វិនកាន់ផុងមិចកែ្នកញាប់ស្អេកឲ្យសញ្ញាទៅគូគន។ ស៊ុយឈីងឆ្ងល់ណាស់ងើបមើលមុខវុនកាន់យីសួរក្លាម:

- ហើយគាត់បញ្ជាឲ្យចាប់ប្ដីប្រពន្ធខ្ញុំនាំទៅក្នុងទឹកកកសម្លាប់ផ្ទាល់ដៃ ដើម្បីសងសឹកឲ្យក្មួយស្រីផងមែនទេ ?

វិនកាន់ផុងប្រកែក យ៉ាងរហ័ស:

- លោកមានប្រសាសន៍បែបនេះដូចជាធ្ងន់ពេកហើយ ! យើងខ្ញុំអន់ខ្សោយខាងយុទ្ធសិល្បៈជាងលោកឆ្ងាយណាស់ តោះក្លាហានយ៉ាងណាក៏មិនហ៊ានដែរ ។ លោកគ្រូគ្រាន់តែផ្ដាំថាឲ្យស្វែងរកកូនប្រុសលោកទាល់តែឃើញព្រោះគាត់ខ្លួចនោះខ្លាចវង្វេងណាស់ បើពុំនោះសោត វាគេចមិនផុតពីភ្នែកច្រមុះពួកយើងទេ ។

អ្នកស្រីវុនយូស្ដាប់ដល់នេះស្រក់ទឹកភ្នែកប្រាប់គេថ្ងូញថា :

- កូនខ្ញុំស្លាប់ហើយ ! ពិតជាស្លាប់ក្នុងជ្រោះជ្រៅ រលួយសាច់អស់ហើយលោកអើយ !

វិនកាន់ផុងគ្រវីក្បាល :

- ទេ ! ទេ ! ពួកយើងឃើញដានជើងវាច្បាស់ក្រៅឡើងតាមផ្លូវទឹកកកដែលចុះពីភ្នំ បានសេច

ក្តីថាវាគេចខ្លួនបាត់ពីក្អុបាត់ហើយ ។ គួរឲ្យខ្លាចណាស់ម្ល៉ោចមែន ! មនុស្សចាស់មួយគំនររកក្មេងម្នា
មិនឃើញ ! ព្រោះហេតុអស់នេះហើយបានជាលោកគ្រូប្រើប្អូនខ្ញុំមកអញ្ជើញលោកប្រុសលោកស្រី ទៅ
ពិគ្រោះយោបល់ ។

– អឺហ្នឹង ! និយាយទៅនិយាយមក នៅតែហៅខ្ញុំឡើងភ្នំទឹកកកសងជីវិតកូនស្រីពន្ធកគេដដែល តែអង្សាញ់មិញលោកថាមានជីវិតពីរទៀតដែលត្រូវសងនោះ ជាអ្នកណាខ្លះ ?

វុនវ៉ាន់យីតប:

– ពួកយើងទទួលបញ្ជាមកទាំងអស់ ១៨នាក់ហើយយើងបែកគ្នាជាពីរក្រុមទៅជាងណានមួយ, មួយទៀតទៅជាមួយលោកបងចិនស្វែងរកកូនប្រុសលោក, តែសំណាងអាក្រក់ដល់ហើយ !...

ចិនវ៉ាន់ជុងពោលកាត់យ៉ាងប្រញាប់:

– ប្អូនវុនមិនត្រូវនិយាយរឿងហ្នឹងទេព្រោះវាគ្មានទាក់ទងនឹងលោកម្ចាស់ភូមិសានស៊ី ។

–ម៉េចបងថាគ្មានទាក់ទង? ព្រោះតែអាចង្រៃជុងយីហ្នឹងហើយបានជាបងជួនិងបងស៊ុនស្លាប់ ! ម្យ៉ាងទៀតយើងមិនទាន់ដឹងថាអ្នកណាជាសត្រូវយើងផងត្រឡប់ទៅវិញដំរាបលោកគ្រូថាម៉េចទៅ ? ប្រែលោកគ្រូខឹងកាច់ដៃបងបាក់ជួចបងហ៊ុនណា ! លោកម្ចាស់ភូមិស្គាល់គេច្រើនគួរពិងគាត់ស៊ើប ខ្លះដែរក្រែងបានលទ្ធផលខ្លះ ។

ចិនវ៉ាន់ជុងនឹកដល់ហ៊ុនវ៉ាន់លី ក៏ក័យ បើកសិទ្ធិឲ្យវុនវ៉ាន់យីដោយតបថា :

– បាន, ប្អូននិយាយទៀតចុះ ។

–លោកម្ចាស់មានជ្រាបទេ ប្រហែលបីថ្ងៃមុនយើងបានដំណឹងថា ជនម្នាក់ត្រកូលវ៉ូមានបញ្ជា សំរិទ្ធ ហើយពួនក្នុងភូមិហូវជានធ្វើជាអ្នកលក់នំបង្ខាញ់ ។ បងប្អូនយើងទាំងប្រាំបួននាក់ គ្រោះគ្នាដោយសម្ងាត់ យល់ថាការដើររកហាប់ឈ្មោះស៊ុជុងយីមិនងាយសម្រេចដូចបំណងទេ ក្នុងជប់ឆ្នាំនេះបើយើងរកមិនឃើញ យើងមិនអាចត្រឡប់ទៅភ្នំទឹកកកវិញឡើយ ។ ហេតុនេះហើយ បានជាយើងខំស្វែងរកផ្ទាំងបញ្ជាសំរិទ្ធក្រែងរួចទោសខ្លះទោះរកកូនលោកមិនឃើញក៏មិនអីដែរ ទ ! ពេលយើងកំពុងពិគ្រោះគ្នានោះអ្នកខ្លះស្តីឲ្យកូនលោកថា នៅក្មេងសោះម្តេចក៏ចិត្តធំម្ល៉េះ, ត្រូវ ជាជាច់ខាត! ស្រាប់តែមានមនុស្សចាស់ម្នាក់សើចហាស ៗ ពោលថាអស្ចារ្យមែន! ក្មេងរបៀបហ្នឹង មានណាស់ណា! ក្មេងតូចមានចិត្តក្លាហានយើងត្រូវតែសរសើរ,ម្តេចឲ្យវាស្លាប់ទៅវិញ? **(នៅមាន**

ដំកល់ទុកតាមលេខ ២៨៩ ចុះថ្ងៃទី ១៤-៥-៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់

Khmer Story Lovers